# ការវាយតម្លៃទូទាំងរដ្ឋ៖ អ្វីដែលគ្រួសារចាំបាច់ត្រូវដឹងអំពីការប្រើប្រាស់លទ្ធផលការវាយតម្លៃ ដោយ ACCESS និង Alternate ACCESS

រៀងរាល់ឆ្នាំ សិស្សនៅរដ្ឋ Minnesota ដែលបានកំណត់ថាជាអ្នកសិក្សាភាសាអង់គ្លេស (ELs) ត្រូវធ្វើតេស្តវាយតម្លៃភាពស្ទាត់ជំនាញភាសាអង់គ្លេសមួយក្នុងចំណោមការវាយតម្លៃនានាដូចខាងក្រោមបន្ថែមពីលើការវាយតម្លៃ MCA ឬ MTAS ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវរបស់សហព័ន្ធនិងរដ្ឋ៖

- ការវាយតម្លៃ ACCESS (ACCESS សម្រាប់ ELLs)
- ការវាយតម្លៃ Alternate ACCESS (Alternate ACCESS សម្រាប់ ELLs)

សិស្ស ELs ភាគច្រើនធ្វើតេស្តវាយតម្លៃ ACCESS ប៉ុន្តែសិស្សដែលទទួលបានសេវាអប់រំពិសេស និងបំពេញតាមលក្ខខណ្ឌតម្រូវសិទ្ធិទទួលបាន អាចនឹងត្រូវធ្វើតេស្តវាយតម្លៃ Alternate ACCESS ជាជំនួស។

ការវាយតម្លៃលើភាពស្ទាត់ជំនាញភាសាអង់គ្លេស ផ្តល់ព័ត៌មានអំពីវឌ្ឍនភាពរបស់សិស្សនៅក្នុងការសិក្សាភាសាអង់គ្លេសផ្នែកអំណាន សំណេរ ការស្តាប់ និងការនិយាយ។

របាយការណ៍សិស្សម្នាក់ៗ (ISR) ផ្តល់លទ្ធផលវាយតម្លៃ ACCESS ឬ Alternate ACCESS របស់សិស្សនីមួយៗ។




- លទ្ធផលនេះគឺជា ***កម្រិតវាស់ស្ទង់មួយ*** ទៅលើវឌ្ឍនភាពរបស់សិស្សអ្នកនៅក្នុងការសិក្សាភាសាអង់គ្លេស ដូចបានរៀបរាប់ដោយស្តង់ដាអភិវឌ្ឍភាសាអង់គ្លេសរបស់ WIDA។
- របាយការណ៍នេះរួមបញ្ចូលនូវលទ្ធផលសម្រាប់ផ្នែកភាសានីមួយៗ រួមជាមួយនឹងការរៀបរាប់ថាតើកម្រិតស្ទាត់ជំនាញនីមួយៗមានន័យដូចម្តេច។
- លទ្ធផលនៃសមាសភាគនីមួយៗ តំណាងឲ្យកម្រិតជំនាញភាសាអង់គ្លេសសរុបរួមពីផ្នែកភាសាអង់គ្លេសចំនួនបួនដែលបានធ្វើតេស្ត។ កម្រិតភាពស្ទាត់ជំនាញនៃភាសា គឺជាការវាស់ស្ទង់ថាតើសិស្សកំពុងបន្តកសាងបំណិនភាសាអង់គ្លេសជាបន្តបន្ទាប់កម្រិតណា។ នៅពេលសិស្សឈានដល់កម្រិតខ្ពស់បំផុតនៃភាពស្ទាត់ជំនាញភាសាអង់គ្លេស ពួកគេលែងត្រូវការសេវាគាំទ្រផ្នែកភាសាទៀតហើយ។



លទ្ធផលត្រូវបានប្រើប្រាស់ដើម្បី ***ត្រួតពិនិត្យ*** ថាតើបំណិនភាសាអង់គ្លេសរបស់សិស្សកំពុងអភិវឌ្ឍដូចម្តេច។

- សាលារៀន អាចប្រើប្រាស់លទ្ធផលនេះដើម្បីធ្វើការសម្រេចអំពីកម្មវិធីភាសាអង់គ្លេស និងការបង្រៀន។
- គ្រូអាចប្រើប្រាស់លទ្ធផលនេះដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍភាសាអង់គ្លេសនៅក្នុងថ្នាក់រៀន។
- លទ្ធផលវាយតម្លៃ ACCESS ត្រូវបានប្រើប្រាស់ដើម្បីកំណត់លើភាពស្ទាត់ជំនាញភាសាអង់គ្លេស និងពេលវេលាដែលត្រូវឲ្យសិស្សចាកចេញពីកម្មវិធី EL។



សំណួរដែលត្រូវសួរសិស្សរបស់អ្នក៖

- តើចំណុចខ្លាំងរបស់អ្នកនៅក្នុងការសិក្សាភាសាអង់គ្លេសមានអ្វីខ្លះ ហើយតើមានបញ្ហាលំបាកអ្វីខ្លះ?
- តើអ្នកអាចពិភាក្សានៅសាលាជាមួយនរណា ដើម្បីទទួលបានជំនួយ ឬសាកសួរសំណួរ?

សំណួរដែលត្រូវសាកសួរគ្រូរបស់កូនសិស្សអ្នក៖

- តើអ្នកអាចទទួលបានព័ត៌មានថ្មីៗអំពីវឌ្ឍនភាពរបស់កូនសិស្សខ្ញុំបានដូចម្តេច?
- តើសេវាអ្វីខ្លះដែលមានផ្តល់ជូននៅសាលាដើម្បីគាំទ្រដល់កូនសិស្សរបស់ខ្ញុំ?

# ការវាយតម្លៃទូទាំងរដ្ឋ ផ្តល់ព័ត៌មានអំពីផែនការអប់រំរដ្ឋ Minnesota

## ត្រួតពិនិត្យការអនុវត្តស្តង់ដា

- ស្តង់ដានោះកំណត់អំពីការរំពឹងទុកសម្រាប់ការរៀននិងបង្រៀនសិស្ស។
- ការវាយតម្លៃទូទាំងរដ្ឋ៖ តំណាងឲ្យព័ត៌មានអំពីការសិក្សារបស់សិស្សទៅលើស្តង់ដានោះ។
- សាលារៀនសាធារណៈ និងមណ្ឌលសិក្សាធិការ ប្រើប្រាស់លទ្ធផលទាំងនេះសម្រាប់ជាផ្នែកមួយនៃប្រព័ន្ធវាយតម្លៃដែលមានតុល្យភាព និងគ្រប់ជ្រុងជ្រោយ។
- ព័ត៌មានដែលបានមកពីប្រព័ន្ធវង្វាយតម្លៃរបស់មណ្ឌលសិក្សាធិការ (ថ្នាក់រៀន មណ្ឌលសិក្សាធិការ និងការវាយតម្លៃប្រចាំរដ្ឋ) សហការគ្នាដើម្បីដឹកនាំការបង្រៀននិងរៀនតាមស្តង់ដានោះ។

## ផ្តល់អាទិភាពដល់សមភាព

- ព័ត៌មានបានមកពីប្រព័ន្ធវង្វាយតម្លៃដែលមានតុល្យភាពនិងគ្រប់ជ្រុងជ្រោយ អាចប្រើប្រាស់ជាការណែនាំដើម្បីធានាថាសិស្សគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាពខ្ពស់ ដោយពុំគិតពីពូជសាសន៍ ឬកូដ ZIP របស់ពួកគេទេ។
- លទ្ធផលវាយតម្លៃរបស់សិស្ស  អាចប្រើប្រាស់ដើម្បីផ្ទៀងផ្ទាត់ក្រុមសិស្ស សាលារៀន និងមណ្ឌលសិក្សាធិការ ដើម្បីកំណត់ក្នុងករណីដែលអាចមានវិសមភាពជាមូលដ្ឋាន និងគូសបញ្ជាក់អំពីការអនុវត្តការបង្រៀនដែលអាចទទួលបានផលល្អ។

## ផ្តល់លទ្ធផលដែលមានសុពលភាព

- អ្នកអប់រំរដ្ឋ Minnesota និងសមាជិកសហគមន៍ ចូលរួមក្នុងការអភិវឌ្ឍតេស្តក្នុងដំណាក់កាលជាច្រើន និងជាដៃគូដ៏សំខាន់នៅក្នុងកិច្ចការនេះ។
- មានការត្រួតពិនិត្យយ៉ាងហ្មត់ចត់ និងការកំណត់សុពលភាពនៃលទ្ធផល មុនពេលរាយការណ៍។
- ចំណុចទាំងពីរនេះធានាបានថា លទ្ធផលវាយតម្លៃទូទាំងរដ្ឋគឺជាកម្រិតវាស់ស្ទង់ដែលមានសុពលភាព និងអាចទុកចិត្តបានទៅលើការសិក្សាតាមស្តង់ដានៅពេលសិស្សធ្វើតេស្ត។

ចាប់តាំងពីខែមីនា ឆ្នាំ2020 អ្នកអប់រំ សិស្ស និងគ្រួសារបានឆ្លងកាត់ការប្រែប្រួលខ្លាំងគួរឲ្យកត់សម្គាល់ និងយ៉ាងស៊ីជម្រៅនៅក្នុងការបង្រៀននិងរៀន ក៏ដូចជាសុខុមាលភាពសង្គមនិងផ្លូវចិត្តផងដែរ។ សំខាន់ត្រូវចងចាំចំណុចនេះនៅពេលបកស្រាយលើលទ្ធផលវាយតម្លៃ ដោយសារតែការប្រែប្រួលនេះបានឆ្លុះបញ្ចាំងឲ្យឃើញនៅក្នុងពិន្ទុរបស់សិស្ស ប៉ុន្តែពិបាកក្នុងការពិចារណាឲ្យបានត្រឹមត្រូវ។

**សំណួរ?**

សម្រាប់ព័ត៌មានបន្ថែមអំពីថាតើអ្នកសិក្សាភាសាអង់គ្លេសកំពុងរីកចម្រើនដូចម្តេចនៅសាលារៀនរបស់អ្នក សូមចូលទៅកាន់ទំព័រកម្រិតលទ្ធផលវង្វាយតម្លៃ *ACCESS* សម្រាប់ *ELLs*  នៅលើតារាងព្រឹត្តិបត្រពិន្ទុរដ្ឋ Minnesota។

ប្រសិនបើអ្នកមានសំណួរអំពីលទ្ធផល MCA ឬ MTAS របស់សិស្សអ្នក សូមទាក់ទងទៅកាន់សាលារៀនអ្នក។ ប្រសិនបើអ្នកមានសំណួរអំពីស្តង់ដាសិក្សា ឬការវាយតម្លៃរបស់រដ្ឋ Minnesota សូមទាក់ទងតាមរយៈ mde.testing@state.mn.us.

mn DEPARTMENT OF EDUCATION